ភ្នំពេញថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី១៤ ខែមិថុនាឆ្នាំ២០១៧នេះ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) នឹងរៀបចំ វេទិការ កម្មវិធីបើកសម្ពោធគម្រោង ស្តីពី **ពង្រឹងសង្គមស៊ីវិល ដើម្បីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ និងប្រកបដោយចីរភាពនៅកម្ពុជា។** ថវិកាសម្រាប់គម្រោងនេះមានចំនួន ១,៥លានអឺរ៉ូ ដែលជាការផ្តល់ហិរញ្ញប្បទានរួមគ្នាដោយសហភាពអឺរ៉ុប (EU) និងអង្គការ Bread for the World (BfdW) សម្រាប់រយៈពេល ៤២ខែ ដោយចាប់ផ្តើមពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

គោលបំណងនៃការរៀបចំកម្មវិធីដើម្បី៖

- បើកសម្ពោធជាផ្លូវការ និងលើកកម្ពស់ភាពអាចមើលឃើញរបស់គម្រោង។
- ណែនាំបទអន្តរាគមន៍របស់គម្រោងទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗរបស់ខ្លួន។
- លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការប្តេជ្ញាចិត្តរបស់ភាគីពាក់ព័ន្ធសំខាន់ៗឆ្ពោះទៅរកការសម្រេចបានគោលបំណងរបស់គម្រោង។

អ្នកចូលរួម៖

កម្មវិធីបើកសម្ពោធគម្រោងនឹងមានអ្នកចូលរួម ១២០នាក់មកពីស្ថាប័ននានាដូចជា មន្ត្រីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយ។

**អាស្រ័យហេតុនេះ សូមអញ្ជើញអ្នកសារព័ត៌មានជាតិ អន្តរជាតិ ចូលរួមយកព័ត៌មានទៅតាម ពេលវេលា និងទីកន្លែងដូចខាងក្រោម។**

**ពេលវេលា៖ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៧ ចាប់ពីម៉ោង ៨ព្រឹក រហូតដល់ 5 រសៀល។**

**ទីកន្លែង៖ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។**

ឯកសារជូនភ្ជាប់៖ របៀបវារៈជាភាសាខ្មែរ និងឯកសារផ្សេងៗទៀត

ទំនាក់ទំនង៖ លោក ព្រំ វាសនា អ្នកឯកទេសផ្នែកទំនាក់ទំនង ទូរស័ព្ទលេខ: ០១២ ៦៣៧ ១០១ / ០១០ ៣៩៩ ២២២



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
ToulTompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia